# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តឧត្តរមានជ័យ

<u>សំណុំរឿងព្រហ្មទណ្ឌលេខ ៧៨</u>

ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២

<u>សំណុំរឿងជំនុំជម្រះលេខ ៨១</u>

ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣

<u>សាលក្រមព្រហ្មទណ្ឌលេខ ៥៥"ខ"/១៦៣</u>

ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តឧត្តរមានជ័យ

បានបើកសវនាការជាសាធារណៈ នៅសាលជំនុំជម្រះនៃសាលាដំបូងខេត្តឧត្តរមានជ័យ នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ ពេលព្រឹក ដោយមានសមាសភាពដូចតទៅ:

### ចៅក្រមជំនុំជម្រះ

លោក [redacted] ជាអនុប្រធាន នៃសាលាដំបូងខេត្តឧត្តរមានជ័យ

### តំណាងអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ជាក្រឡាបញ្ជី នៃសាលាដំបូងខេត្តឧត្តរមានជ័យ

### មេធាវី

លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

### ដើម្បីជំនុំជម្រះ

សំណុំរឿងព្រហ្មទណ្ឌលេខ ៧៨ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] **ចាន់រិទ្ធ** ហៅ **អ៊ាប** ភេទប្រុស អាយុ៤៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរធ្វើស្រែចម្ការ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពត និងមានទីលំនៅបច្ចុប្បន្នភូមិទួលស្វាយ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ប្រពន្ធឈ្មោះ [redacted] សេងគា មានកូនចំនួន០៣នាក់ ឪពុកឈ្មោះ [redacted] ផន (ស្លាប់) ម្តាយឈ្មោះ [redacted] ឃុន (ស្លាប់) កម្រិតវប្បធម៌ថ្នាក់ទី០៧ ទោសពីមុន គ្មាន (ក្នុងឃុំ)

ជាប់ចោទពីបទ **រំលោភលើទំនុកចិត្ត និងលួចលក់អចលនវត្ថុអ្នកដទៃ** ប្រព្រឹត្តនៅចំណុចភូមិថ្នល់កែង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ និងមាត្រា **២៥៥** នៃច្បាប់ភូមិបាល។

-**បានឃើញ** ដីកាដំណោះស្រាយ (បញ្ជូនសំណុំរឿងទៅជំនុំជម្រះ) លេខ ០៥៩/២០២៣ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តឧត្តរមានជ័យ។

-**បានឃើញ** ដីកាចាត់តាំងចៅក្រមជំនុំជម្រះ លេខ ០៨៣ ដចត/២៣ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តឧត្តរមានជ័យ។

### <u>អង្គហេតុមានដូចតទៅ៖</u>

Scanned with CamScanner

កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ កម្លាំងកងរាជអាវុធហត្ថស្រុកអន្លង់វែង បានទទួលបណ្តឹងរបស់ប្រជាពលរដ្ឋចំនួន០៥គ្រួសារ ដែលបានប្តឹងលើឈ្មោះ [redacted] ចាន់រិទ្ធ ភេទប្រុស កើតឆ្នាំ១៩៧៥ រស់នៅភូមិទួលស្វាយ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដោយឈ្មោះនេះបានធ្វើសកម្មភាពដូចជា៖ កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៨ ឈ្មោះ [redacted] ចាន់រិទ្ធ បានខ្ចីរថយន្តម៉ាក កាំមរី ស៊េរីឆ្នាំ១៩៩៦ ចំនួន០១គ្រឿង, ម៉ូតូម៉ាក អ៊ីមអេសអ៊ិច ចំនួន ០១គ្រឿង, ទូរស័ព្ទដៃម៉ាក អុបប៉ូ ចំនួន០១គ្រឿង ពីឈ្មោះ [redacted] ចាន់ថូ ភេទស្រី កើតឆ្នាំ១៩៨០ រួចយកទៅលក់ និងយកទៅ បញ្ចាំបាត់ ដោយសរុបជាទឹកប្រាក់ចំនួន ៤,០០០ (បួនពាន់ដុល្លារអាមេរិក) បន្ទាប់មកឈ្មោះនេះ ក៏បានប្រគល់ដីមួយកន្លែងឱ្យឈ្មោះ [redacted]ាន់ថូ ទំហំ២០ម៉ែត្រ គុណនឹង ២០ម៉ែត្រ ស្ថិតនៅភូមិទួលស្វាយ ឃុំត្រពាំងតាវ ស្រុកអង់ផង ខេត្តឧត្តរមានជ័យ ក្រោយមកស្រាប់តែឈ្មោះ [redacted] ចាន់រិទ្ធ ឱ្យប្រពន្ធកូនទៅជេរប្រមាថលើឈ្មោះ [redacted] ចាន់ថូ ព្រមទាំងគម្រាមកំហែងថា បើឈ្មោះ [redacted] ចាន់ថូ មិនព្រមចេញពីទីតាំងដីខាងលើនឹងឱ្យគេទៅធ្វើបាប។ នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៩ ឈ្មោះ [redacted] ចាន់រិទ្ធ បានលក់ដីឱ្យឈ្មោះ [redacted] ឡា ភេទប្រុស កើតឆ្នាំ១៩៧៨ ទំហំ២០ម៉ែត្រ គុណនឹង២៧ម៉ែត្រ ក្នុងតម្លៃ ៥,០០០,០០០ (ប្រាំលាន) រៀល, នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២០ លក់ឱ្យឈ្មោះ [redacted]ណួន ភេទប្រុស ឆ្នាំ១៩៦២ និងនៅថ្ងៃ ទី១៥ ខែតុលា ឆ្នាំ២០២១លក់ឱ្យឈ្មោះ [redacted]រឹង ភេទប្រុស កើតឆ្នាំ១៩៨៦ ដោយសន្យាថានឹងរត់ការកាត់ប្លង់ដីឱ្យ ប៉ុន្តែ ក្រោយមានការសួរនាំដល់អាជ្ញាធរភូមិឃុំ ទើបដឹងថា ទីតាំងដីដែលឈ្មោះ [redacted] ចាន់រិទ្ធិ បានយកមកលក់ឱ្យនោះ គឺជាដីកម្មសិទ្ធិរបស់អ្នកដទៃ។ នៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ ឈ្មោះ [redacted] ចាន់រិទ្ធិ បានជួលដីដាំដំឡូងមី ទំហំ ១០ហិចតា នៅ ភូមិទំនប់ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ឱ្យទៅឈ្មោះ [redacted]មន ភេទប្រុស កើតឆ្នាំ១៩៧៩ ក្នុងតម្លៃ ៦០០,០០០ (ហុកសិបម៉ឺន) រៀល ក្នុងមួយឆ្នាំ ដោយបានប្រគល់ប្រាក់កក់ចំនួន ៣,០០០,០០០ (បីលាន) រៀល មុនរួច ប៉ុន្តឈ្មោះ [redacted] ចាន់រិទ្ធ បែរជាយកដីនោះទៅជួលឱ្យអ្នកផ្សេងទៀតទៅវិញ។ ក្រោយការសាកសួរឈ្មោះ [redacted] ចាន់រិទ្ធិ បានសារភាពថា ខ្លួនពិតជាបានលក់ដី និងជួលដីឱ្យដើមបណ្តឹងខាងលើប្រាកដមែន។ ចំពោះការប្តឹងចោទប្រកាន់របស់ឈ្មោះ ខូយ ចាន់ថូ ដែលថាខ្លួន យករថយន្តម៉ាកកាំម៉ារី សេរីឆ្នាំ១៩៩៦ ចំនួន០១គ្រឿង, ម៉ូតូម៉ាក អឹមអេសអ៊ិច ចំនួន០១ គ្រឿង, ទូរស័ព្ទដៃម៉ាក អូបប៉ូ ចំនួន០១គឿង យកទៅលក់ និងកាត់ដីឱ្យនោះ ខ្លួនសូមបដិសេធ ប៉ុន្តែផ្អែកតាមលិខិតបញ្ជាក់ ពីចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ របស់លោក [redacted]ញ៉ាញ បង្ហាញថា ឈ្មោះ [redacted] ចាន់រិទ្ធិ ពិតជាបានប្រព្រឹត្តដូចការចោទ ប្រកាន់មែន។

**នាពេលសវនាការ**

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ក្រោយពីបានស្តាប់សម្តី និងសំណូមពរចុងក្រោយរបស់ជនជាប់ចោទ។

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

**យល់ឃើញថា៖**

Scanned with CamScanner

១.ជនជាប់ចោទឈ្មោះ [redacted] ចាន់រិទ្ធ ហៅ អ៊ាប ភេទប្រុស អាយុ៤៨ឆ្នាំ បានឆ្លើយថា ខ្លួនមិនបានប្រព្រឹត្ត ដូចការចោទប្រកាន់នោះទេ។ ខ្លួនស្គាល់ឈ្មោះ [redacted] ចាន់ថូ តែខ្លួនអត់បានខ្ចី ទូរស័ព្ទ ដី ឡាន ទៅបញ្ចាំនោះទេ។ កន្លងមកធ្លាប់បានទូទាត់គ្នាជាមួយគាត់រួចរាល់ហើយ តែគាត់មកប្តឹងខ្លួន ចំពោះរឿងឡានខ្លួនធ្លាប់ទិញលក់ ជាមួយប្តី ឈ្មោះ [redacted] ចាន់ថូ ដោយកាតគ្រីអស់យូរឆ្នាំ ហើយរឿងម៉ូតូ និងទូរស័ព្ទ គ្រួសាររបស់គាត់មិនដឹងនោះទេ។ ឈ្មោះ [redacted] ចាន់ថូ បែកបាក់គ្នា រួចមកសុំដីរបស់ខ្លួននៅ ខ្លួនបានឱ្យដីប្រាំម៉ែត្រតែគាត់រំកិល១០ម៉ែត្រ ទើបខ្លួនឱ្យរុះរើចេញ អាឡូវគាត់ចេញហើយ។ ចំពោះឈ្មោះ [redacted] ឡា ដោយសារខ្លួនមានមនោសញ្ចេតនាថា គាត់នៅឆ្ងាយមកសុំដីខ្លួន ខ្លួនក៏បានឱ្យចំនួន ១៥ម៉ែត្រ គាត់ក៏សុំថែមទៀត រហូតសរុប ២៧ម៉ែត្រ ក្រោយមកគាត់ឱ្យខ្លួនធ្វើលិខិតមួយឱ្យគាត់ ដើម្បីឱ្យគាត់ និងគ្រួសាររស់នៅបានកក់ក្តៅ ដើមឡើយដីនោះជារបស់បងធម៌ក្រុមប្រឹក្សាឃុំ ហើយដីនោះមានការ ប្រគល់ឱ្យខ្លួនពេលដែលមានការសេសសល់ ហើយដីនោះខ្លួនលក់ឱ្យឈ្មោះ [redacted] ឡា ដោយមិនមានលិខិតស្នាម ឱ្យទេ ប្តង់ត្រឹមឃុំ លក់បានប្រាក់ខ្លួនម្នាក់ឯង ពេលនោះឈ្មោះ [redacted] ឡា ឱ្យម្តងបន្តិចៗ។ ខ្លួនមានអ្នកទិញបញ្ជាក់ថា បងធម៌ឈ្មោះ [redacted] សេងអាន នៅទំនប់ថ្មីឱ្យដីនោះ ដោយគាត់បានប្រគល់ឱ្យខ្លួន ប្រាកដមែន។ ខ្លួនលក់ដីឱ្យឈ្មោះ [redacted] ណូន នៅថ្ងៃទី២២ ខែកញ្ញា។ ដីនោះ ឈ្មោះ [redacted] រឹង ជាប្អូនធម៌របស់ឈ្មោះ [redacted] ឡា បានមកជួយធ្វើផ្ទះរបស់ ខ្លួន គាត់បានសុំដីខ្លួន ខ្លួនបានឱ្យដីទៅគាត់ ចំនួន ៩ម៉ែត្រ គុណនឹង ២០ម៉ែត្រ ខ្លួនក៏មិនបានធ្វើលិខិតស្នាមទេ។ ចំពោះដីរបស់ឈ្មោះ [redacted] ណូន ទំហំ ៨ម៉ែត្រ គុណនឹង ៣០ម៉ែត្រ នៅភូមិទំនប់ ដើមឡើយឈ្មោះ [redacted] រិទ្ធ និង ឈ្មោះ គីម ណូន និយាយគ្នារឿងលុយប្រគល់ឱ្យខ្លួន ដោយខ្លួនបានទទួលចំនួន ១៦០០ ដុល្លាអាមេរិក ដោយមិន បានទទួលដូចឈ្មោះ [redacted] ណូន ឱ្យឈ្មោះ [redacted] រិទ្ធ យកមកឱ្យខ្លួនទេ ហើយដីនោះ គឺដីខ្លួនទិញពីគេ ដោយសារ ដីនោះយូរពេកទើបឈ្មោះ [redacted] ណូន ទារមកលុយវិញ។ ដីដាំឡូងដែលខ្លួនបានឱ្យឈ្មោះ [redacted] មន គឺជាដីខ្លួននៅភូមិ ទំនប់ ឃុំត្រពាំងប្រាសាទ ដោយពេលនោះឈ្មោះ [redacted] សួរថា ជួលអត់ដីចម្ការ ខ្លួនថា [redacted] រិទ្ធ ឯងនាំគេមើលដី ទៅ ពេលនោះគាត់នាំទៅមើល រួចក៏បានជួលតម្លៃ ៧០ម៉ឺនរៀល ក្នុង ០១ហិចតា ក្រោយមកគាត់មិនធ្វើ ដោយថា ដីដុះព្រៃខ្លួន និងខ្លាចមីន។ ចំពោះលុយ ៣លាននោះខ្លួនទទួលបានតែចំនួន ៦០ម៉ឺនរៀល តែប៉ុណ្ណោះ។ ចំពោះ ឡាន ទិញពីឈ្មោះ [redacted] រឹង ពេលទិញអត់មានសាក្សីដឹងលឺទេ។ ចំពោះម៉ូតូ និងទូរស័ព្ទ សូមបដិសេធ។ ដីប្រគល់ ឱ្យឈ្មោះ [redacted] ចាន់ថូ ក្រោយទិញឡាន។ គាត់ទិញឡាន គឺក្រោយពេលគាត់ ([redacted] ចាន់ថូ) បែកបាក់គ្នាយូរហើយ ។ ពេលបែកបាក់គ្នាបានមកសុំដីខ្លួននៅ។ ខ្លួនជាប្រជាជនធម្មតា។ ដីខ្លួនបានពីឈ្មោះ [redacted] តួត ពីមុន។ ដីឱ្យឈ្មោះ [redacted] ឡា លក់អត់មានអាជ្ញាធរដឹងលឺទេ។ ពេលដីបានពីឈ្មោះ [redacted] តួក អត់បានធ្វើឯកសារទេ។ ឈ្មោះ [redacted] សេង ហាន ទិញដីពីឈ្មោះ [redacted] តួក។ ពាក់ព័ន្ធដីឈ្មោះ [redacted] ឡា ឈ្មោះ [redacted] រឹង គឺដីតែមួយជាមួយគ្នា។ ដីលក់ឱ្យឈ្មោះ [redacted] ណូន ដីផ្សេងៗរបស់ខ្លួន ទិញពី ឈ្មោះ [redacted] សុង ជាពលរដ្ឋម្ចាស់ដី ដោយលក់ឱ្យឈ្មោះ [redacted] ណូន តម្លៃ ៣៥០០ ដុល្លាអាមេរិក អត់ធ្វើឯកសារទេ ខ្លួនលក់តាមរយៈឈ្មោះ [redacted] រិទ្ធ គាត់ទាក់ទងឈ្មោះ [redacted] ណូន ខ្លួន ទើបទទួលលុយបានតែ ១៦០០ ដុល្លាអាមេរិក ទេ ក្រោយមកត្រូវស៊ីញ៉េ នៅភូមិឃុំយូរពេក ទើបទុកសិនយូរមិន មែនមានបញ្ហាអ្វីទេ។ ឈ្មោះ [redacted] មន គឺឈ្មោះ [redacted] សេងហាន បានឱ្យខ្លួនយកដីគាត់មកជួលឱ្យឈ្មោះ [redacted] មន ជួល១ ហិចតា តម្លៃ ៦០ម៉ឺនរៀល ដីសរុប១០ហិចតា អត់ពាក់ព័ន្ធដីព្រៃទេបានធ្វើឯកសារអោយលក់ដូរ។ ខ្លួន និងឈ្មោះ [redacted] រិទ្ធ គាត់ធ្លាប់នៅផ្ទះខ្លួន ពេលជួលដីឈ្មោះ [redacted] រិទ្ធ គាត់បានយកលក់ខ្លះដែរ។ ឈ្មោះ [redacted] សេងហាន ទិញដី

Scanned with CamScanner

ពីឈ្មោះ [redacted] តួក ឈ្មោះ [redacted] សេងហាន ទិញដី ចំនួន ១៩ម៉ែត្រ គុណនឹង ២៧ម៉ែត្រ ឱ្យខ្លួន ដីប្តូងដាក់ឈ្មោះ [redacted] សេងហាន ដែលគាត់ទិញពីឈ្មោះ [redacted] តួក។ ដីជាកម្មសិទ្ធិរបស់ខ្លួន ដីតម្លៃ ១៦០០ ឈ្មោះ [redacted] រិទ្ធ យកមកឱ្យខ្លួនជាប្រាក់កក់ តែមិនបានសរសេរជាឯកសារពេលទិញលក់ទេ។ ពាក់ព័ន្ធឈ្មោះ [redacted] មន មិនមែនដីខ្លួនផ្ទាល់ទេ ដីឈ្មោះ [redacted] សេងហាន ឱ្យខ្លួនចាត់ចែងជួលឱ្យគេ។ ពាក់ព័ន្ធឈ្មោះ [redacted] ចាន់ថូ គឺខ្លួនអត់បានខ្ចីឡាន ទូរស័ព្ទពីគាត់ ទេ។

២.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់ថូ ភេទស្រី អាយុ៤២ឆ្នាំ បានឆ្លើយថា ឈ្មោះ [redacted] ចាន់រិទ្ធ បានខ្ចីឡាននៅកាស៊ីណូ ខ្ចីពីប្តីខ្លួន គាត់សួរថាលក់អត់ ៣៥០០ ដុល្លាអាមេរិក ក្រោយលក់ឃើញឱ្យលុយតែ ១០០០ ដុល្លាអាមេរិកមកខ្លួន។ ចំពោះម៉ូតូ ក៏យកបញ្ចាំ ដោយឱ្យដីក្បាល ២០ម៉ែត្រ គុណនឹង ២០ម៉ែត្រ ក្រោយមកម៉ូតូ ប្តីខ្លួនក៏ទៅជាមួយគាត់មួយសារទៀត។ ពេលប្តីខ្លួនមិនទាន់លែងលះ គាត់ទិញទូរស័ព្ទ ហើយគាត់ខ្ចីទូរស័ព្ទ ពេលនោះឈ្មោះ [redacted] ចាន់រិទ្ធ បានខ្ចីទៀត ម៉ូតូខ្ចី២ដង។ ចំពោះដីគាត់ឱ្យមិនមានប្លង់ទេ។ ពេលបែកបាក់គាត់ឱ្យនៅលើដីគាត់ ១០ម៉ែត្រ គាត់ធ្លាប់និយាយថា ឱ្យខ្លួនធ្វើប្រពន្ធចុងគាត់ខ្លួនមិនព្រម ទើបខ្លួនជួលគេឱ្យរើផ្ទះចេញពីដីគាត់។ ឈ្មោះ [redacted] ចាន់រិទ្ធ ឱ្យលុយតែ១០០០ទេ ចំពោះដីខ្លួនទទួលបានក៏ត្រឹមតែ ៨ម៉ែត្រ កន្លះនោះទេ ពេលបែកគ្នាជាមួយប្តីខ្លួន។ អត់ទាមទារសំណងទេ តែចង់ឱ្យគាត់សងខ្លួន ចំនួន ៤០០០ ដុល្លាអាមេរិក។ ពេលលែងលះប្តី ឆ្នាំ២០១៩ ពេលគាត់យកឡានបញ្ចាំនៅកាស៊ីណូមុនខ្លួនលែងលះគ្នា ទូរស័ព្ទតម្លៃ ៤០០ដុល្លាអាមេរិកជាង ដោយឈ្មោះ [redacted] ចាន់រិទ្ធ ខ្ចីឡានពីប្តីខ្លួនទៅបញ្ចាំ ប្តីខ្លួនសួរថា លក់ឡានគាត់អត់ បើលក់ទើបឈ្មោះ [redacted] ចាន់រិទ្ធ យកឡានទៅបញ្ចាំកើត។ ហើយឡានរបស់ខ្លួនលក់វគ្គក្រោយគាត់ខ្ចីវគ្គមុន។

៣.តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឡា ភេទប្រុស អាយុ៤៤ឆ្នាំ បានឆ្លើយថា ខ្លួនទិញដីពីឈ្មោះ [redacted] ចាន់រិទ្ធ ក្រោយមកដឹងថា មិនមែនរបស់គាត់។ ដី ៧ម៉ែត្រ គុណនឹង ២០ម៉ែត្រ តម្លៃ ៥លានរៀល ។ ដីនោះមេភូមិថា ដីរបស់ឈ្មោះ [redacted] តួក ដំបូងមិនដឹងថាជារបស់ឈ្មោះ [redacted] តួក ទេ ដីនោះមិនបានធ្វើឯកសារ ព្រោះស្គាល់គ្នាថា ចាំធ្វើពេលក្រោយ។ ខ្លួនទារសំណង ១០០០០ដុល្លាអាមេរិក។ ដីវាលខ្លួនអ្នកកាន់កាប់ធ្វើផ្ទះលើដីនោះ។ ខ្លួនដឹងថា ដីនោះជារបស់ឈ្មោះ [redacted] តួក ដោយសារមេភូមិប្រាប់។ ឈ្មោះ [redacted] តួក អត់បានអះអាងថា បានលក់ដីឱ្យឈ្មោះ [redacted] ចាន់រិទ្ធ នោះទេ ទើបខ្លួនប្តឹងឈ្មោះ [redacted]ាន់រិទ្ធ។ ឈ្មោះ [redacted] ចាន់រិទ្ធ ថា ហែង ពិការចឹងទិញដីអញ់តែម្តងទៅ និយាយទិញលក់ ២ដំណាក់កាល គាត់បានទទួលប្រាក់ ចំនួន បីលានចិតសិបប្រាំម៉ឺនរៀល ថា ចាំរត់ប្លង់ឱ្យរហូតដល់ឆ្នាំ២០២២ គាត់បែរជាយកត្រាក់ទ័រទៅឈូសទាំងដែលគាត់មិនទាន់រត់ប្លង់ឱ្យខ្ញុំបាទ ដោយបានឱ្យធ្វើផ្ទះសិនទៅ។ ឈ្មោះ [redacted] តួក គាត់ប្រាប់ថា ជាដីរបស់គាត់។

៤.តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]រីង ភេទប្រុស អាយុ៣៤ឆ្នាំ បានឆ្លើយថា ខ្លួនបានទទួលលុយពីឈ្មោះ [redacted] ចាន់រិទ្ធ ចំនួន ១លានរៀល។ ខ្លួនទទួលដីពីឈ្មោះ [redacted] ចាន់រិទ្ធ ចំនួន ៩ម៉ែត្រ ដោយសារមានមនោសញ្ចេតនានឹងគ្នាទើបទិញ ១លានរៀល។ ខ្លួនប្តឹងគាត់ដោយសារ ដីនោះមិនមែនជាដីរបស់ឈ្មោះ [redacted] ចាន់រិទ្ធ នោះទេ។ ខ្លួនទាមទារសំណងចំនួន ២លានរៀល។ ខ្លួនបានទិញដីទំហំ ៩ម៉ែត្រ គុណនឹង ២០ម៉ែត្រ ពីឈ្មោះ សូត្រ ចាន់រិទ្ធ ១លានរៀល ដីនោះអត់ខ្លួនមិនហ៊ានធ្វើទេព្រោះមេភូមិមេឃុំមិនរត់ច្បាប់ឱ្យ។

៥.តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ណូន ភេទប្រុស អាយុ៦០ឆ្នាំ បានឆ្លើយថា ដីទិញពីឈ្មោះ [redacted] ចាន់រិទ្ធ តែដោយសាររត់ប្លង់ដីយូរពេក និងជាដីរបស់អ្នកដទៃ ទើបខ្លួនសុំយកលុយវិញ ដីនោះខ្លួនធ្លាប់

Scanned with CamScanner

ទៅភ្ជួរ ហើយគេទៅឃាត់ថាដីគេ ហើយមេភូមិមេឃុំមិនធ្វើឯកសារឱ្យ ទើបខ្លួនទាមទារលុយវិញ ដោយទាមទារសំណង ៥០០០ ដុល្លាអាមេរិក។ ខ្លួនទិញដីនោះ ៣៥០០ ដុល្លាអាមេរិក ដោយបានឱ្យគាត់ ចំនួន ២៤០០ ដុល្លាអាមេរិក និងយកបានលុយមកវិញ ចំនួន ១២០ ដុល្លាអាមេរិក។ ដីនោះមិនបានធ្វើឯកសារអ្វីនោះទេ នៅពេលទិញ។ ដីនោះពីមុនធ្លាប់មានគេដាំដំឡូងតែមិនដឹងថាអ្នកណាដាំនោះទេ ដោយដីនោះ មានក្បាល ទំហំ៤៨ បណ្តោយទំហំ២៣២ ម៉ែត្រ។ ដីនោះខ្លួនថាចូលទៅភ្ជួរតែឈ្មោះ [redacted] ចាន់រិទ្ធ ហាមមិនឱ្យចូលទៅភ្ជួរ ទើបសួរភូមិឃុំបានខ្លួនដឹងមិនមែនដីគាត់។ ការប្រគល់លុយឱ្យគាត់ ២៤០០ ដុល្លាអាមេរិក អត់បានធ្វើលិខិតស្នាមអ្វីនោះទេ ដោយមានសាក្សីក្មួយរបស់ខ្លួនឈ្មោះ [redacted] រិទ្ធ ប្រពន្ធរបស់ខ្លួន ជាអ្នកប្រគល់លុយឱ្យផ្ទាល់។

៦.តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មន ភេទប្រុស កើតឆ្នាំ១៩៧៩ បានឆ្លើយថា ខ្លួនភ្ជួរដីឱ្យឈ្មោះ [redacted] ចាន់រិទ្ធ នៅខែវិច្ឆិកា ខ្លួនភ្ជួរដីឱ្យឈ្មោះ [redacted] ចាន់រិទ្ធ ខ្លួនទាមទារសំណង ចំនួន ៣លានរៀល។ ខ្លួនជួលដីមានឈ្មោះ [redacted] រិទ្ធ ដឹងលឺ។

៧.តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រិទ្ធ ភេទប្រុស អាយុ៤៤ឆ្នាំ បានឆ្លើយថា ដីនោះ ឈ្មោះ [redacted] ចាន់រិទ្ធ ឱ្យឈ្មោះ [redacted] ម៉ន ពិតមែន។ ចំពោះ ឈ្មោះ [redacted] ណូន ធ្លាប់រាប់អានគ្នា។ គាត់បាននាំខ្លួនមកទិញដីគេ ហើយខ្លួនក៏បានចាក់ដីនៅ ២ឆ្នាំ បានដឹងដីនោះមានបញ្ហា។ ឈ្មោះ [redacted] ណូន វេលុយគាត់ តាមវីង និងទៅយកនៅសង្កាត់ផ្ទាល់ ទាំងពីរលើក សរុប ចំនួន ២៤០០ដុល្លាអាមេរិក អត់បានធ្វើឯកសារនោះទេ ព្រោះជឿទុកចិត្តគ្នា។ ដីដែលឈ្មោះ [redacted] ចាន់រិទ្ធ លក់ឱ្យគេនោះជាដីរបស់ឈ្មោះ [redacted] តួក មិនមែនដីរបស់គាត់ផ្ទាល់ទេ។ ខ្លួនអត់ធ្លាប់នៅជាមួយជាប់ទេ ដោយរាប់អានគ្នាចេញចូលៗប៉ុណ្ណោះ ជាទូទៅតែងធ្វើលិខិតទិញលក់ និងប្រគល់ទទួលប្រាក់ខ្លួនជាអ្នករកស៊ីតែជាមួយឈ្មោះ [redacted] ចាន់រិទ្ធ រាប់អានគ្នា អត់បានធ្វើទេ។ ឈ្មោះ [redacted] ម៉ន ដីគាត់នោះគឺ ខ្លួនបានទទួលលុយ ៤០ម៉ឺនរៀល ពេលជួយរឿងដីគាត់។ ឈ្មោះ [redacted] ចាន់ថូ ពាក់ព័ន្ធឡានបញ្ចាំ ខ្លួនគ្រាន់តែដឹងតែមិនបានចូលរួមផ្ទាល់ទេ គ្រាន់តែលឺថា គាត់ធ្លាប់ខ្ចី។ ខ្លួនបានទិញដីពីឈ្មោះ [redacted] ចាន់រិទ្ធ ទំហំ ១៥ម៉ែត្រ គុណនឹង ២០ម៉ែត្រ ស្ថិតនៅក្រោមផ្សារទួលស្វាយ ក្នុងភូមិទួលស្វាយ ឃុំគ្រពាំងតាវ ស្រុកអន្លង់វែង ក្នុងតម្លៃ ២,៥០០ ដុល្លាអាមេរិក។ ក្រោយមកក្នុងអំឡុងឆ្នាំ២០២៣ ខ្លួនបានសម្រេចចិត្តទៅធ្វើប្លង់ជាមួយអាជ្ញាធរភូមិឃុំ តែត្រូវមេឃុំទួលស្វាយបានប្រាប់ថា ដីមានម្ចាស់ត្រឹមត្រូវ និងមានប្លង់ស្របច្បាប់ទៀត មិនមែនជារបស់ឈ្មោះ [redacted] ចាន់រិទ្ធនោះទេ។ ខ្លួនទាមទារតម្លៃដើម ចំនួន ២៥០០ ដុល្លាអាមេរិក តាមកិច្ចសន្យា។

៨.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់ការពិភាក្សាដេញដោលរួចមក ឃើញថាជនជាប់ចោទឈ្មោះ [redacted] ចាន់រិទ្ធ ពិតជាបានប្រព្រឹត្តអំពើរំលោភលើទំនុកចិត្ត និងបទឆបោកលួចលក់អចលនវត្ថុអ្នកដទៃ ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តច្បាប់ ដែលពាក់ព័ន្ធទៅនឹងអង្គហេតុនៃការខ្ចី រថយន្ត ទូរស័ព្ទ និងម៉ូតូដែលជាកម្មសិទ្ធិរបស់ប្តីជនរងគ្រោះឈ្មោះ [redacted] ចាន់ថូ ក្រោយពីបានខ្ចីរួចហើយ ជនជាប់ចោទបានយកទ្រព្យសម្បត្តិទាំងនោះទៅដាក់បញ្ចាំ ដោយពុំមានការដឹងលឺពីជនរងគ្រោះនោះទេ ដូច្នេះនេះជាបទល្មើសរំលោភលើទំនុកចិត្តដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តមាត្រា ១៩០ និង១៩២ នៃក្រមព្រហ្មទណ្ឌ។ ដោយឡែកចំពោះជនរងគ្រោះផ្សេងទៀត ដែលមានឈ្មោះ [redacted] វីង, ឈ្មោះ [redacted] ឡា, ឈ្មោះ [redacted] ទ្ធ, ឈ្មោះ [redacted] ន និងឈ្មោះ [redacted] ណូន ឃើញថា ជនជាប់ចោទឈ្មោះ ចាន់រិទ្ធិ បានប្រើប្រាស់ឧបាយកល កុហកទៅលើជនរងគ្រោះ ដោយអះអាងអំពី

Scanned with CamScanner

កម្មសិទ្ធិនៅលើដីដែលបានជួលទៅឲ្យជនរងគ្រោះថា ជាកម្មសិទ្ធិរបស់ខ្លួន ក្នុងចេតនាចង់ទទួលបានលុយកាក់មួយចំនួនពីជនរងគ្រោះពីការប្រព្រឹត្តបទល្មើសនេះ តំណាងអយ្យការយល់ឃើញថា អំពើនេះជាបទល្មើសឆបោក ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣០៧ និងមាត្រា៧១ នៃក្រមព្រហ្មទណ្ឌ។ ដោយឡែកក្រោយពីបានធ្វើការស្រាវជ្រាវលើអង្គហេតុដែលបានលើកឡើងនៅក្នុងសវនាការនេះ ឃើញថា ដីដែលជនជាប់ចោទបានជួលនោះ គឺជាដីរបស់ឈ្មោះ[redacted] តួក មិនមែនជាដីរបស់ឈ្មោះ [redacted] ចាន់រិទ្ធ នោះទេ ដែលការលួចលក់អចលនវត្ថុរបស់អ្នកដទៃ នេះ គឺជាបទល្មើសតាមបញ្ញត្តិមាត្រា២៩៥ នៃច្បាប់ភូមិបាល ដូច្នេះឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់ទៅលើបទល្មើសរំលោភលើទំនុកចិត្ត និងបទល្មើសឆបោកពីការលួចលក់អចលនវត្ថុអ្នកដទៃ ត្រូវផ្តន្ទាទោសតាមបញ្ញត្តមាត្រា ៣៩១ , មាត្រា៣៩២, មាត្រា ៣៧៧ និងមាត្រា៣៧៦ នៃក្រមព្រហ្មទណ្ឌ និងមាត្រា២៩៥ នៃច្បាប់ភូមិបាល ដូច្នេះស្នើសុំលោកចៅក្រមជួយពិនិត្យ និងសម្រេចផ្តន្ទាទោសតាមច្បាប់។

៩.មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់ការពិភាក្សាដេញដោលរួចមក ឃើញថា កូនក្តីរបស់ខ្លួនបានពាក់ព័ន្ធអង្គហេតុដូចតទៅ ពាក់ព័ន្ធនឹងឈ្មោះ [redacted] ឡា បានទាក់ទងទិញដីពីគាត់ប្រាកដមែន និងបានទារលុយ ចំនួន ៣លានរៀល ដូច្នេះឃើញថា ជាអង្គហេតុរដ្ឋប្បវេណី។ ឈ្មោះ [redacted] ណូន បានទិញដីកូនក្តីរបស់ខ្លួន ទំហំ ៣៨ម៉ែត្រ គុណនឹង ២៣២ម៉ែត្រ កូនក្តីរបស់ខ្លួន បានអះអាងថា ដីគាត់ឈ្មោះ [redacted] ណូន ប្រគល់ឲ្យ ១៦០០ ដុល្លាអាមេរិក តាមការអះអាងរបស់កូនក្តីខ្លួន ការទទួលលុយជាប្រាក់កក់ ដោយថាប្រគល់ប្លង់ដីតាមពេលណាមួយនៃកិច្ចសន្យាតែគាត់មកទាមទារលុយកូនក្តីរបស់ខ្លួនមុនពេលកូនក្តីរបស់ខ្លួនត្រូវអនុវត្តកាតព្វកិច្ច។ ឈ្មោះ [redacted] រឹង កូនក្តីរបស់ខ្លួនអះអាងថា គ្រាន់ការរាប់អាន ទើបបានប្រគល់ដីដែលកូនក្តីរបស់ខ្លួនទទួលបានពីឈ្មោះ[redacted] តួកឲ្យគាត់រស់នៅ ចំពោះប្រាក់ ៥លានរៀល ជាទឹកចិត្តរបស់ឈ្មោះ [redacted] រឹង នោះទេ។ ឈ្មោះ [redacted] ចាន់ថូ គាត់មិនច្បាស់ថ្ងៃខែថា កូនក្តីរបស់ខ្លួនយក ឡានទៅបញ្ចាំទេ ម៉ូតូឡាន ទូរស័ព្ទក៏គ្មានអ្វីយកមកបញ្ជាក់ថា កូនក្តីរបស់ខ្លួនខ្ចីហើយយកទៅបញ្ចាំដែរ។ ការទិញឡានមិនមែនរហូតដល់ឲ្យដីនោះទេ។ ចំពោះដើមបណ្តឹងមួយចំនួនគាត់បានបោះបង់សិទ្ធិដោយខ្លួនឯងមិនអាស្រ័យផលលើដីនោះ។ ខ្លួនស្នើសុំលោកចៅក្រមជំនុំជម្រះលើកលែងការចោទប្រកាន់លើកូនក្តីរបស់ខ្លួន។

១០.តាមចម្លើយរបស់ជនជាប់ចោទ តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងតាមការពិនិត្យភស្តុតាងដែលមាននៅក្នុងសំណុំរឿងរួចមក ឃើញថា កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ នៅចំណុចភូមិថ្នល់កែង ឃុំអន្លង់វែងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ជនជាប់ចោទឈ្មោះ [redacted] **ចាន់រិទ្ធ** ហៅ **អ៊ាប** ភេទប្រុស អាយុ៤៨ឆ្នាំ ពិតជាបានធ្វើសកម្មភាព រំលោភលើទំនុកចិត្ត និងលួចលក់អចលនវត្ថុអ្នកដ៏ទៃ ប្រាកដមែន។

១១.អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ចាន់រិទ្ធ** ហៅ **អ៊ាប** ភេទប្រុស អាយុ៤៨ឆ្នាំ ជាបទល្មើស **រំលោភលើទំនុកចិត្ត និងលួចលក់អចលនវត្ថុអ្នកដ៏ទៃ** តាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ និងមាត្រា **២៥៥** នៃច្បាប់ភូមិបាល។

១២.អំពើប្រព្រឹត្តរបស់ជនជាប់ចោទ បង្កឲ្យមានភាពអសន្តិសុខនៅក្នុងសង្គម និងធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងល្មើសនឹងច្បាប់រដ្ឋផងដែរ។

Scanned with CamScanner

១៣.ជនជាប់ចោទឈ្មោះ [redacted]ចាន់រិទ្ធ ហៅ អ៊ាប ភេទប្រុស អាយុ៤៨ឆ្នាំ ជានីតិជន នាពេលប្រព្រឹត្តបទល្មើស ស្ថិតក្នុងស្ថានពេលដែលអាចយល់ដឹងអំពីលទ្ធផលតាមផ្លូវច្បាប់ចំពោះអំពើរបស់ខ្លួន មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ។

១៤.មានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted]ចាន់រិទ្ធ ហៅ អ៊ាប ភេទប្រុស អាយុ៤៨ឆ្នាំ ពីបទ **រំលោភលើទំនុកចិត្ត និងលួចលក់អចលនវត្ថុអ្នកដទៃ** ប្រព្រឹត្តនៅចំណុចភូមិថ្មល់កែង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២៥៥ នៃច្បាប់ភូមិបាល។

១៥.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]មន ភេទប្រុស កើតឆ្នាំ១៩៧៩ បានឆ្លើយថា ខ្លួនទាមទារសំណងចំនួន ៣លានរៀល។ គប្បីតុលាការពិនិត្យ និងសម្រេចតាមទំហំនៃព្យសនកម្មជាក់ស្តែង។

១៦.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឡា ភេទប្រុស អាយុ៤៤ឆ្នាំ បានឆ្លើយថា ខ្លួនទាមទារសំណងចំនួន ១០,០០០ដុល្លាអាមេរិក។ គប្បីតុលាការពិនិត្យ និងសម្រេចតាមទំហំនៃព្យសនកម្មជាក់ស្តែង។

១៧.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ណូន ភេទប្រុស អាយុ៦០ឆ្នាំ បានឆ្លើយថា ខ្លួនទាមទារសំណងចំនួន ៥,០០០ដុល្លាអាមេរិក។ គប្បីតុលាការពិនិត្យ និងសម្រេចតាមទំហំនៃព្យសនកម្មជាក់ស្តែង។

១៨.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ចាន់ថូ ភេទស្រី អាយុ៤២ឆ្នាំ បានឆ្លើយថា ខ្លួនទាមទារសំណងចំនួន ៤,០០០ដុល្លាអាមេរិក។ គប្បីតុលាការពិនិត្យ និងសម្រេចតាមទំហំនៃព្យសនកម្មជាក់ស្តែង។

១៩.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រិទ្ធ ភេទប្រុស អាយុ៤៤ឆ្នាំ បានឆ្លើយថា ខ្លួនទាមទារតម្លៃដើមចំនួន ២៥០០ដុល្លាអាមេរិក តាមកិច្ចសន្យា។ គប្បីតុលាការពិនិត្យ និងសម្រេចតាមទំហំនៃព្យសនកម្មជាក់ស្តែង។

## ហេតុដូច្នេះតុលាការ
## វិនិច្ឆ័យសេចក្តី

១.**ផ្តន្ទាទោសឈ្មោះ** [redacted]**ចាន់រិទ្ធ** ហៅ **អ៊ាប** ភេទប្រុស អាយុ៤៨ឆ្នាំ ជនជាតិខ្មែរ (អត្តសញ្ញាណខាងលើ)

ដាក់ពន្ធនាគារកំណត់រយៈពេល **០៦(ប្រាំមួយ)ខែ**

ពីបទ **រំលោភលើទំនុកចិត្ត និងលួចលក់អចលនវត្ថុអ្នកដទៃ** ប្រព្រឹត្តនៅចំណុចភូមិថ្មល់កែង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២៥៥ នៃច្បាប់ភូមិបាល។

២.បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted]ចាន់រិទ្ធ ហៅ អ៊ាប ភេទប្រុស អាយុ៤៨ឆ្នាំ សងសំណងជម្ងឺចិត្តចំនួន ០៣លានរៀល មកឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]មន ភេទប្រុស កើតឆ្នាំ១៩៧៩។

៣.បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted]ចាន់រិទ្ធ ហៅ អ៊ាប ភេទប្រុស អាយុ៤៨ឆ្នាំ សងសំណងជម្ងឺចិត្តចំនួន ០៥(ប្រាំ)លានរៀល មកឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឡា ភេទប្រុស អាយុ៤៤ឆ្នាំ ការទាមទារលើសពីនេះ បដិសេធចោល។

Scanned with CamScanner

៤.បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] ចាន់រិទ្ធ ហៅ អ៊ាប ភេទប្រុស អាយុ៤៨ឆ្នាំ សងសំណងជម្ងឺចិត្ត ចំនួន ១០(ដប់)លានរៀល មកឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ណួន ភេទប្រុស អាយុ៦០ឆ្នាំ ការទាមទារលើសពីនេះ បដិសេធចោល។

៥.បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] ចាន់រិទ្ធ ហៅ អ៊ាប ភេទប្រុស អាយុ៤៨ឆ្នាំ សងសំណងជម្ងឺចិត្ត ចំនួន ០៤(បួន)ពាន់ដុល្លាអាមេរិក មកឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់ធូ ភេទស្រី អាយុ៤២ឆ្នាំ ការទាមទារលើសពីនេះ បដិសេធចោល។

៦.បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted]ចាន់រិទ្ធ ហៅ អ៊ាប ភេទប្រុស អាយុ៤៨ឆ្នាំ សងសំណងជម្ងឺចិត្ត ចំនួន ២,៥០០(ពីរពាន់ប្រាំរយ)ដុល្លាអាមេរិក មកឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រិទ្ធ ភេទប្រុស អាយុ ៤៤ឆ្នាំ ការទាមទារលើសពីនេះ បដិសេធចោល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចាន់រិទ្ធ និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វីង, ឈ្មោះ [redacted] ចាន់ធូ, ឈ្មោះ [redacted] ឡា, ឈ្មោះ [redacted] មន, ឈ្មោះ [redacted] រិទ្ធ និងឈ្មោះ [redacted] ណួន។

បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់៕

ថ្ងៃពុធ ៤ កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅឧត្តរមានជ័យ,ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣

**ក្រឡាបញ្ជីសវនាការ**
**ហត្ថលេខា និងត្រា**
[redacted]

**ចៅក្រមជំនុំជម្រះ**
**ហត្ថលេខា និងត្រា**
[redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ៤ កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅឧត្តរមានជ័យ,ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ឧត្តរមានជ័យ,ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣

**ចៅក្រម**

[redacted]

Scanned with CamScanner